| កិច្ចតែងការ | |
|---|---|
| **មុខវិជ្ជា** | សិក្សាសង្គម |
| **ប្រធានបទ** | ចលនាច្នៃប្រឌិត |
| **ចំណងជើងមេរៀន** | តន្រ្តីរាំអង្គុយ ដកស្រង់ចេញពី "រឿង តើអ្នកពូកែអី?" |
| **កម្រិត** | ទាប |
| **គោលបំណង** | អនុវត្តបំនិនចលនាធំ ការរីកចម្រើនរាងកាយ និងចលនា |
| **បំណិនសម្បទា** | ត្រិះរិះពិចរណា និងវិភាគ។ |
| **ចរិយាសម្បទា** | ស្រឡាញ់ចូលចិត្តច្រៀងបទចម្រៀងសហការគ្នា និងចូលរួមយ៉ាងសប្បាយរីករាយ។ |
| **គ្រូបង្រៀន (ផលិតសម្ភារឧបទេស)** | រកបទសម្រៀងដែលអ្នកចង់ចាក់ ឬច្រៀង។ |
| **កុមារ** | ឈរជាក្រុម ប៉ុន្តែកុំឱ្យគៀកគ្នាពេក ជៀសវាងប៉ះគ្នា នៅពេលធ្វើកាយវិការ។ |
| **រៀបចំ** | -រៀបចំបទចម្រៀងឱ្យរួចរាល់<br>-ប្រាប់ពីចំណងជើង អត្ថន័យបទចម្រៀងនិងរបៀបធ្វើកាយវិការ។<br>-ច្រៀងចម្រៀង និងធ្វើកាយវិការតាមខ្លឹមសារបទចម្រៀង។ |

| សកម្មភាពគ្រូបង្រៀន | មាតិកា | សកម្មភាពសិស្ស |
|---|---|---|
| ១.ប្រាប់ពួកគេថាគឺជាផ្លែដូងដែលមានចងព្យួរនៅលើដើមឈើមួយ។<br>២.ខណៈពេលដែលបទចម្រៀងកំពុងចាក់ ឱ្យក្មេងៗទាំងអស់រាំធ្វើដូចជាផ្លែដូងកំពុងយោងទៅវិញទៅមកទៅតាមខ្យល់។<br>៣.ប៉ុន្តែនៅពេលដែលបទចម្រៀងបញ្ឈប់ ឱ្យពួកគេអង្គុយចុះភ្លាមៗ ដូចជាផ្លែដូងធ្លាក់ចុះអញ្ចឹង ។<br>៣.ចាប់ផ្តើមចាក់បទចម្រៀងម្តងទៀតបន្ទាប់ពីបានឈប់សម្រាក បន្តិច។<br>៤.នៅពេលដែលក្មេងៗទាំងអស់កំពុងអង្គុយនោះប្រាប់ឱ្យក្មេងៗទាំងអស់ក្រោកឈរម្តងទៀត និងចាក់បទចម្រៀងម្តងទៀត ។<br>៥.សម្រាប់ការប្រែប្រួល អ្នកអាចសួរក្មេងទាំងអស់ធ្វើអ្វីៗផ្សេងទៀតនៅពេលដែលបទចម្រៀងកំពុងចាក់។ ពួកគេអាចសម្តែងជាផ្លែដូងធ្លាក់ត្រូវជើងម្ខាង ហើយលោតជើងម្ខាងព្រោះឈឺពេក។ ឬក៏លើកដៃឡើងធ្វើជាដើមដូង ដែលត្រូវខ្យល់បក់បោក រេចុះ រេឡើង។ | ១.ល្បែងនេះអាចលេងជាការប្រកួតក៏បានដែរ។<br>២.ក្មេងម្នាក់ដែលអង្គុយរហូតនោះគេនឹងត្រូវចាញ់ ហើយទៅឈររាំនៅខាងមុខ។<br>៣.បន្តការលេងល្បែងមួយនេះរហូតដល់ក្មេងៗនៅសល់ម្នាក់ឬ២នាក់គឺជាអ្នកឈ្នះ។ | ១.ស្វែងរកកន្លែងដែលមានទីធ្លាទូលាយ ដែលមិនអាចប៉ះគ្នាបាន។<br>២.រាំនៅនឹងកន្លែងឱ្យបានល្អតែត្រូវប្រយ័ត្នកុំឱ្យមានការប៉ះគ្នាឱ្យសោះ<br>៣.នៅពេលដែលបទចម្រៀងបញ្ឈប់ ឱ្យពួកគេអង្គុយចុះភ្លាមៗតាមដែលអាចធ្វើទៅបាន ។<br>៤.ប្រសិនបើអ្នកចាញ់ហើយគឺត្រូវរាំនៅកន្លែងផ្សេងបាន ។<br>៥.ល្បែងនេះអាចលេងបានយ៉ាងសប្បាយ តែមិនអាចធ្វើឱ្យមានសម្លេងខ្លាំងពេកទេ ព្រោះធ្វើឱ្យស្តាប់សម្លេងបទចម្រៀង មិនលឺ។<br>៦.ស្តាប់គ្រូ និងធ្វើតាមសេចក្តីណែនាំ និងធ្វើតាមគាត់។ |